MHSOAC
Mental Health Services
Oversight and Accountability Commission

1300 17th Street, Suite 1000
Sacramento, CA 95811
(916) 445-8696
mhsoac@mhsoac.ca.gov

ថ្ងៃ ទី 1 តុលា 2011

ចំពោះ សហគមន៍សុខភាពផ្លូវចិត្ត នៅ Stanislaus និងខោនធីនៅជិតខាង ៖

វេទិកាសហគមន៍នឹងត្រូវធ្វើនៅថ្ងៃ ទី 8 ខែធ្នូ 2011, ដើម្បីពិភាក្សាវែកញ្ញែក អំពីការប៉ះទង្គិចលើ Proposition 63, ច្បាប់សេវាកម្មសុខភាពផ្លូវចិត្ត (Mental Health Services Act, MHSA) នៅ Stanislaus និងខោនធីនៅជិតខាង។ វេទិកាសហគំន៍ត្រូវបានឧបត្ថម្ភដោយគណកម្មការត្រួតពិនិត្យនិងគណនេយ្យភាព (MHSOAC) រដ្ឋ California និងជួយសម្រួលដោយគណកម្មការ MHSOAC ពីរ the Client and Family គណៈកម្មការដឹកនាំអតិថិជន និងគ្រួសារ និងគណកម្មការ វប្បធម៌ និងគណកម្មការសមត្ថភាពភាសាវិទ្យា។

វេទិកាសហគមន៍នឹងត្រូវធ្វើឡើងពីម៉ោង 3:00 ដល់ម៉ោង 6:30 ល្ងាច។

កន្លែង ៖ មជ្ឈមណ្ឌល The Seasons Multicultural Event Center
945 McHenry Avenue
Modesto, CA 95350

ទូរស័ព្ទ ៖ (209) 523-4000 (សំរាប់ទិសដៅ)

ជាពិសេស គណកម្មការ MHSOAC គឺមានការចាប់អារម្មណ៍ចង់ស្តាប់ពីភាគីហ៊ុនអំពី តើសេវាកម្ម របស់ MHSA និងការឧបត្ថម្ភនានាដែលផ្តល់មូលនិធិជាលទ្ធផលនៃ Proposition 63 នោះមានអ្វី ខុសប្លែកសំរាប់ពួកគេ គ្រួសាររបស់គេ ឬសហគមន៍ដែរឬទេ។ សមាជិកគណកម្មការ MHSOAC និងបុគ្គលិកនឹងជួយសម្រួលការពិភាក្សាទម្រង់ពាក់កណ្តាល ជាមួយការចូលរួម របស់ភាគីហ៊ុន ដែលរៀបរាងឡើងសំរាប់ទាញយកការឲ្យយោបល់ និងទស្សនៈចម្រុះ។ ព័ត៌មាន និងរឿងរ៉ាវនានា ប្រមែប្រមូលបានតាមរយៈការពិភាក្សានឹងត្រូវសង្ខេប ប្រចាំឆ្នាំហើយបានប្រើដើម្បីផ្តល់ជាយោបល់ ទៅគណកម្មការ MHSOAC អំពីរបៀបដែលជនទាំងនោះមានបទពិសោធជាមួយ MHSA នៅ ក្នុងសហគមន៍ទាំងឡាយទូទាំងរដ្ឋ California។ ព័ត៌មាននេះ នឹងត្រូវពិចារណាគិតគូរ ដោយ MHSOAC ក្នុងការកែទម្រង់ទិសដៅនយោបាយនាពេលអនាគត។

វេទិកាសហគមន៍មិនមែនជាការត្រួតពិនិត្យជាផ្លូវការ ឬសវនកម្មរបស់កម្មវិធី MHSA នៅ Stanislaus និងខោនធីនៅជិតខាង។ គោលដៅនៃវេទិកាគឺដើម្បីគាំទ្រដល់ការប្រស្រ័យទាក់ទង របស់ MHSOAC ជាមួយនឹងសាធារណជននៅរដ្ឋCalifornia និងផ្តល់ឱ្យកាសឲ្យគេស្តាប់ រឿងរ៉ាវ ផ្ទាល់ពីភាគីហ៊ុនទាំងឡាយ។ គោលដៅពិសេសៗសំរាប់វេទិកាសហគមន៍មានរួមនូវ ៖

1. ផ្តល់ឱកាសសំរាប់គណកម្មការត្រួតពិនិត្យនិងគណនេយ្យភាពឲ្យស្តាប់ដោយផ្ទាល់ ពីអតិថិជន សមាជិកគ្រួសារ និងភាគីហ៊ុនផ្សេងៗទៀតអំពីបទពិសោធរបស់គេជាមួយច្បាប់សេវាកម្មសុខភាពផ្លូវចិត្ត (MHSA) នៅក្នុងសហគមន៍តាមតំបន់ទូទៅក្នុងរដ្ឋ California ដោយរួមទាំងអ្វីដែលប្រើការបាន និងអ្វីជាការប្រឈមមុខ។
2. ប្រមូលផ្តុំព័ត៌មាននិងរឿងរ៉ាវទាំងឡាយ ទាំងជាវិជ្ជមាន និងអវិជ្ជមាន អំពីបទពិសោធតាមតំបន់ និងការប៉ះទង្គិចនានារបស់ MHSA។
3. ពន្យាការផ្សព្វផ្សាយឲ្យដឹងជាសាធារណៈ និងការអប់រំ អំពី Proposition 63, ច្បាប់សេវាកម្មសុខភាពផ្លូវចិត្ត (MHSA) និង MHSOAC។
4. ពន្យានូវទិស្សមានភាពរបស់ MHSOAC ដោយបើកឲ្យមានវេទិកាសហគមន៍ទូទាំងរដ្ឋ California រួមទាំងតំបន់ក្នុងរដ្ឋដែលគណកម្មការមិនដែលបានជួបនៅទីនោះ។
5. ព័ត៌មានដែលប្រមូលបាននៅឯវេទិកាសហគមន៍នឹងត្រូវធ្វើវិភាគ សង្ខេបនិងរាយការណ៍ប្រចាំឆ្នាំទៅឲ្យគណកម្មការ ដើម្បីកែទម្រង់ការអភិវឌ្ឍន៍ កែទម្រង់ទិសដៅនយោបាយនាពេលអនាគត។

យើងទន្ទឹងរង់ចាំទទួលចាត់ចែងធ្វើវេទិកាសហគមន៍នេះនៅ Modesto ហើយ សង្ឃឹមនឹងឃើញភាគីហ៊ុនជាច្រើនមកពី Stanislaus និងខោនធីនៅជិតខាងមកចូលរួម។

អ្នកបកប្រែភាសាអេស្ប៉ាញ៉ុលនឹងមាននៅឯកន្លែងវេទិកាសហគមន៍ Modesto។ អ្នកបកប្រែភាសាដ៏ទៃៗទៀតនឹងមានជូនទៅតាមសម្នើសុំជាមុន។ សូមទាក់ទងមក MHSOAC តាមអ៊ីម៉ែល mhsoac@mhsoac.ca.gov ឬទូរស័ព្ទ (916) 445-8696 សំរាប់សម្នើទាំងនេះ។

ដោយសារកន្លែងមានកំរិតយើងមានការរីករាយបើសិនជាលោកអ្នកអាចបំរុងកន្លែងទុកជាមុន បើសិនជាលោកអ្នកមានគំរោងមកចូលរួម ឬមកចូលរួមជាក្រុម។ សូមផ្ញើអ៊ីម៉ែលមកបំរុងកន្លែងតាម mhsoac@mhsoac.ca.gov ឬ (916) 445-8696។

បើសិនជាអ្នក មានសំណួរនានាអំពីវេទិកាសហគមន៍ សូមទាក់ទងមក Matt Lieberman ឬ Peter Best បុគ្គលិករបស់ MHSOAC: matthew.lieberman@mhsoac.ca.gov ឬ (916) 445-8696 ឬ peter.best@mhsoac.ca.gov ឬ (916) 445-8696។

យើងទន្ទឹងរង់ចាំជួបជាមួយលោកអ្នកនៅ ថ្ងៃទី 8 ខែធ្នូ នៅ Modesto។

Richard Van Horn, MHSOAC អនុប្រធាន
គណកម្មការត្រួតពិនិត្យនិងគណនេយ្យភាពសេវាកម្មសុខភាពផ្លូវចិត្ត

ប្រធាន គណៈកម្មការវប្បធម៌ និងសមត្ថភាពផ្នែកភាសាសាស្ត្រ

Eduardo Vega, ស្នងការ
គណកម្មការត្រួតពិនិត្យនិងគណនេយ្យភាពសេវាកម្មសុខភាពផ្លូវចិត្ត
ប្រធាន គណៈកម្មការដឹកនាំអតិថិជន និងគ្រួសារ

Ralph Nelson Jr., M.D., ស្នងការ,
គណកម្មការត្រួតពិនិត្យនិងគណនេយ្យភាពសេវាកម្មសុខភាពផ្លូវចិត្ត;
អនុប្រធាន គណៈកម្មការដឹកនាំអតិថិជន និងគ្រួសារ